**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ................ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## លក្ខខណ្ឌនៃការផ្តល់ ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

## សំរេច

**មាត្រា ១.-**

អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ត្រូវផ្តល់ចំពោះតែសម្បទានិកដែលមានអាជ្ញាប័ណ្ណស្វែងរុករកប៉ុណ្ណោះ ក្នុងគោលបំណងស្វែងរុករក និងជីកយករ៉ែណាដែលមានជម្រករ៉ែមានប្រសិទ្ធិភាពសេដ្ឋកិច្ច ហើយស្ថិតនៅតែក្នុងរង្វង់ព្រំដែននៃអាជ្ញាប័ណ្ណស្វែងរុករក ។

**មាត្រា ២.-**

សម្បទានិក ដែលមានអាជ្ញាប័ណ្ណស្វែងរុករក អាចដាក់សំណុំលិខិតពាក្យសុំអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ នៅពេលណាក៏បាននៅក្នុងរយៈពេលសុពលភាពនៃអាជ្ញាប័ណ្ណស្វែងរុករក មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដូចខាងក្រោម :

(១) ពាក្យសុំអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ (មានបិទតែម២.០០០រៀល) ចំនួន ១ច្បាប់
(២) ផែនទី និងទីតាំងស្នើសុំជីកយករ៉ែ .................................................... ចំនួន ១ច្បាប់
(៣) កម្មវិធីការងារ និងថវិកាដែលនឹងគ្រោងអនុវត្តនៅក្នុងរយៈពេលជីកយករ៉ែ .......... ចំនួន ១ច្បាប់
ដែលក្នុងនោះត្រូវបង្ហាញ និងអធិប្បាយអំពី :

ក- ផែនការ និងបច្ចេកទេសជីកយករ៉ែ ផែនការអណ្តូងរ៉ែ និងផែនការប្រព្រឹត្តិកម្ម
ខ- គ្រឿងសម្ភារៈបរិក្ខាសំរាប់ដំណើការជីកយករ៉ែ
គ- របាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងផែនការការពារបរិស្ថាន
ឃ- ផែនការ និងបច្ចេកទេសស្តារការដ្ឋានជីកយករ៉ែឡើងវិញ និងថវិកាបំរុងសំរាប់ការស្តារការដ្ឋានជីកយករ៉ែឡើងវិញ
ង- ផែនការរកទីផ្សារលក់ផលិតផលរ៉ែ
ច- របាយការណ៍ស្តីពីការវិភាគហិរញ្ញវត្ថុ ការកំណត់ថ្លៃផលិតកម្មរ៉ែ និងថ្លៃលក់ផលិតផលរ៉ែ
ឆ- កម្មវិធីជ្រើសរើសពលករកម្ពុជាឱ្យចូលធ្វើការ និងបណ្តុះបណ្តាលបច្ចេកទេស
ជ- ផែនការប្រើប្រាស់ទំនិញ និងសេវាដែលមាននៅកម្ពុជា ។

**មាត្រា ៣.-**

អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ដែលផ្តល់ឱ្យសម្បទានិកមួយលើក១ មានតម្លៃសំរាប់រយៈពេល ប្រាំ (០៥) ឆ្នាំ ។

**មាត្រា ៤.-**

សម្បទានិក ដែលមានអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ អាចដាក់សំណុំលិខិតពាក្យសុំពន្យារបន្តអាជ្ញាប័ណ្ណ រហូតដល់ជម្រករ៉ែអស់លក្ខណៈសេដ្ឋកិច្ច មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដើម្បីពិនិត្យ និងសំរេចយ៉ាងហោចណាស់កៅសិប (៩០) ថ្ងៃ មុនផុតសុពលភាពនៃអាជ្ញាប័ណ្ណដែលកំពុងមាន ដោយភ្ជាប់មកជាមួយនូវ :

(១) ពាក្យសុំការពន្យារបន្តអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ............................ ចំនួន ១ច្បាប់
(២) របាយការណ៍ស្តីពីលទ្ធផលនៃការជីកយករ៉ែ ការស្តារការដ្ឋានជីកយករ៉ែ ការបង់សួយសារ ថ្លៃឈ្នួលដីប្រចាំឆ្នាំ ពន្ធលើប្រាក់ចំណេញ និងពន្ធអាករពាក់ព័ន្ធផ្សេងទៀត ដោយភ្ជាប់មកជាមួយសក្ខីប័ត្រដើម ..................................................................... ចំនួន ១ច្បាប់
(៣) តារាងតុល្យភាពគណនេយ្យ និងតុល្យភាពគណនីសំរាប់មូលនិធិស្តារឡើងវិញ ............ ចំនួន ១ច្បាប់
(៤) របាយការណ៍ស្តីពីការបណ្តុះបណ្តាលបច្ចេកទេស ................................................ ចំនួន ១ ច្បាប់
(៥) ផែនការ និងបច្ចេកទេសជីកយករ៉ែ និងផលិតកម្មរ៉ែ ផែនការស្តារការដ្ឋានដ្ឋានជីកយករ៉ែ ដោយភ្ជាប់មកជាមួយនូវសេចក្តីអធិប្បាយលំអិត សំរាប់រយៈពេលបន្តនៃអាជ្ញាប័ណ្ណថ្មី .. ចំនួន ១ច្បាប់
(៦) កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និង ផែនការប្រើប្រាស់ទំនិញ និងសេវានៅកម្ពុជា សំរាប់រយៈពេលបន្តនៃអាជ្ញាប័ណ្ណថ្មី ................................................................. ចំនួន ១ច្បាប់

## មាត្រា ៥.-

សម្បទានិក ដែលមានអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ មានបំណងផ្ទេរសិទ្ធិទាំងស្រុងនៃអាជ្ញាប័ណ្ណនោះទៅឱ្យភាគីមួយទៀត ត្រូវដាក់ពាក្យសុំផ្ទេរសិទ្ធិមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលដើម្បីពិនិត្យ និងសំរេចដោយភ្ជាប់មកជាមួយនូវ :

(១) លិខិតស្នើសុំផ្ទេរសិទ្ធិទាំងស្រុងនៃអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ពីភាគីផ្ទេរសិទ្ធិដោយមានការបញ្ជាក់មូលហេតុច្បាស់លាស់ ..................... ចំនួន ១ច្បាប់

(២) លិខិតស្នើសុំទទួលសិទ្ធិ និងការទទួលខុសត្រូវទាំងស្រុង ពីភាគីទទួលសិទ្ធិ ....... ចំនួន ១ច្បាប់

(៣) របាយការណ៍ស្តីពីការជំរះបំណុលសួយសារ ថ្លៃឈ្នួលដីប្រចាំឆ្នាំ និងពន្ធអាករពាក់ព័ន្ធផ្សេងទៀត ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងសក្ខីប័ត្រដើម .................. ចំនួន ១ច្បាប់

(៤) ច្បាប់ចម្លងវិញ្ញាបនប័ត្រចុះបញ្ជីរបស់ភាគីទទួលសិទ្ធិ នៅអគ្គនាយកដ្ឋានធនធានរ៉ែ ........................................................ ចំនួន ១ច្បាប់

(៥) របាយការណ៍ស្តីពីសមត្ថភាពហិរញ្ញវត្ថុ ឬតុល្យភាពហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយ ៣ឆ្នាំ របស់ភាគីទទួលសិទ្ធិ ដោយមានការបញ្ជាក់ពីស្ថាប័នហិរញ្ញវត្ថុ ឬ សវនកម្មណាមួយដែលបានទទួលសិទ្ធិធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា .......................... ចំនួន ១ច្បាប់

(៦) បទពិសោធន៍កន្លងមករបស់ភាគីទទួលសិទ្ធិ ក្នុងវិស័យធនធានរ៉ែ ឬឧស្សាហកម្ម ដែលពាក់ព័ន្ធ ........................................................................ ចំនួន ១ ច្បាប់

(៧) កម្មវិធីការងារ និងថវិកាដែលនឹងគ្រោងអនុវត្តនៅក្នុងរយៈពេលជីកយករ៉ែ របស់ភាគីទទួលសិទ្ធិ ..................................................................... ចំនួន ១ច្បាប់

ដែលក្នុងនោះត្រូវបង្ហាញ និងអធិប្បាយអំពី :

- ក- ផែនការ និងបច្ចេកទេសជីកយករ៉ែ ផែនការអណ្តូងរ៉ែ និងផែនការប្រព្រឹត្តិកម្ម
- ខ- គ្រឿងសម្ភារៈបរិក្ខាសំរាប់ដំណើការជីកយករ៉ែ
- គ- របាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងផែនការការពារបរិស្ថាន
- ឃ- ផែនការ និងបច្ចេកទេសស្តារការដ្ឋានជីកយករ៉ែឡើងវិញ និងថវិកាបំរុងសំរាប់ការស្តារការដ្ឋានជីកយករ៉ែឡើងវិញ
- ង- ផែនការរកទីផ្សារលក់ផលិតផលរ៉ែ
- ច- របាយការណ៍ស្តីពីការវិភាគហិរញ្ញវត្ថុ ការកំណត់ថ្លៃផលិតកម្មរ៉ែ និងថ្លៃលក់ផលិតផលរ៉ែ
- ឆ- កម្មវិធីជ្រើសរើសពលករកម្ពុជាឱ្យចូលធ្វើការ និងបណ្តុះបណ្តាលបច្ចេកទេស
- ជ- ផែនការប្រើប្រាស់ទំនិញ និងសេវាដែលមាននៅកម្ពុជា ។

## មាត្រា ៦.-

រាល់លក្ខខ័ណ្ឌនៃការផ្តល់ ការពន្យាបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ដែលបាន កំណត់នៅក្នុងកិច្ចព្រមព្រៀងស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រុមហ៊ុន ឬ អាជីវករ ដែលមានពីមុន ហើយផ្ទុយទៅនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**កន្លែងទទួល :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន
- សាលាខេត្ត-ក្រុង
- កាលប្បវត្ត-ឯកសារ